# ពាក្យស្លោករបស់អង្គការអាយស៊ីស៊ី៖ ពង្រឹងសហគមន៍ ជាតិរឹងមាំ




*"សមភាពយេនឌ័រ មិនមែនគ្រាន់តែជាគោលដៅមួយដែលប្រទេសមួយត្រូវសម្រេចឱ្យបាននោះទេ វាជាបុរេលក្ខខណ្ឌមួយដែលប្រទេសនីមួយៗ ត្រូវសម្រេចឱ្យបានជាមុនសិន មុនពេលប្រទេសនោះអាចដោះស្រាយបញ្ហាប្រឈមផ្សេងទៀតដូចជា ការកាត់បន្ថយភាពក្រីក្រ ការជម្រុញឱ្យមានការអភិវឌ្ឍន៍មួយប្រកបដោយចីរភាព និងការកសាងអភិបាលកិច្ចល្អ"។ ប្រសាសន៍របស់លោក កូហ្វី អាណាន់ អតីតអគ្គលេខាធិការអង្គការសហប្រជាជាតិ។ គម្រោងអាយស៊ីស៊ី-ហ្វាស (អភិវឌ្ឍន៍ គ្រួសារ និងសាលារៀន) នៅខេត្តស្វាយរៀង បច្ចុប្បន្ននេះកំពុងធ្វើការពង្រឹងសិទ្ធិអំណាចទៅសហគមន៍មូលដ្ឋាន ដើម្បីធ្វើការលុបបំបាត់ផ្នត់គំនិតអវិជ្ជមាន និងការរើសអើងផ្នែកយេនឌ័រ នៅក្នុងគ្រួសារនិងសហគមន៍។ ការងារមួយនេះ គឺផុសចេញពីផ្នត់គំនិតរបស់អង្គការអាយស៊ីស៊ី ដែលគិតថាបុរស និងស្ត្រីត្រូវបានបង្កើត ឡើងមានលក្ខណៈស្មើគ្នា ហើយមានគុណតម្លៃ និងសិទ្ធិដូចៗគ្នា។ អង្គការអាយស៊ីស៊ី ជឿជាក់ថានៅពេលដែលបុរស និងស្ត្រីមានការចូលរួម និងការរួមចំណែកស្មើគ្នានោះ ផលប៉ះពាល់វិជ្ជមានដ៏ធំមួយនឹងអាចកើតមានឡើងបានដោយសារតែការចូលរួមចំណែកទាំងអស់នេះ។*

ចាប់តាំងពីឆ្នាំ២០១៥មក គម្រោងហ្វាស បាននឹងកំពុងធ្វើការបញ្ជ្រាបសមភាពយេនឌ័រទៅក្នុងការអនុវត្តគម្រោងរបស់ខ្លួន។ ជាលទ្ធផល សមភាពយេនឌ័រនៅក្នុងសហគមន៍គោលដៅរបស់ គម្រោងហ្វាស មានការប្រសើរឡើងខ្លាំង។ អាជ្ញាធរមូលដ្ឋានក៏មានការយល់ដឹងកាន់តែច្បាស់អំពីបញ្ហាយេនឌ័រ ច្បាប់ និងសិទ្ធិ ដូចជាសិទ្ធិនារី និងសិទ្ធិកុមារ។ បច្ចុប្បន្ននេះមានស្ត្រីជាច្រើនត្រូវបានតែងតាំងជាអ្នកដឹកនាំនៅក្នុងសហគមន៍មូលដ្ឋាន ឧទាហរណ៍៖ ធ្វើការងារដែលទាក់ទងទៅនឹងបញ្ហាស្ត្រី និងកុមារ។ ពិតជាល្អណាស់នៅពេលដែលឃើញថា អ្នកភូមិបានយល់ដឹងពីសារៈសំខាន់នៃសមភាពយេនឌ័រ ជាពិសេសសមភាពយេនឌ័រនៅក្នុងគ្រួសារ ហើយទាំងអស់នេះ បានចូលរួមចំណែកក្នុងការកាត់បន្ថយអំពើហិង្សាក្នុងគ្រួសារ។

រឿងដ៏ជោគជ័យមួយអំពីការបញ្ជ្រាបយេនឌ័ររបស់ គម្រោងហ្វាស គឺផ្តោតទៅលើស្ត្រីម្នាក់ ដែលមានភាពក្លាហានក្នុងការប្រកួតប្រជែងជាមួយនឹងទំនៀមទំលាប់សង្គម និងវប្បធម៌ តាមរយៈការចាប់យកតួនាទីជាអ្នកដឹកនាំក្នុងសកម្មភាពអភិវឌ្ឍន៍សហគមន៍របស់គាត់។ បន្ទាប់ពីបានចូលរួមជាមួយ គម្រោងហ្វាស ចាប់តាំងពីឆ្នាំ២០១៥ មកគាត់បានក្លាយទៅជាមនុស្សមួយដ៏សំខាន់ និងជាគំរូមួយដ៏ល្អ ដោយសារតែការប្តេជ្ញាចិត្តខ្ពស់របស់គាត់ចំពោះការអភិវឌ្ឍសហគមន៍ និងការពង្រឹងសិទ្ធិអំណាច។ គាត់ត្រូវបានបោះឆ្នោតឱ្យក្លាយទៅជាប្រធានក្រុមជួយខ្លួនឯង (ក.ជ.ខ) តាមរយៈសមាជិកក្រុមរបស់គាត់ ដោយសារតែគាត់មានសមត្ថភាព និងចំណេះដឹងដែលទទួលបានតាមរយៈវគ្គបណ្តុះបណ្តាលផ្សេងៗពី គម្រោង ហ្វាស ដូចជាការកត់ត្រាបញ្ជីគណនេយ្យ ទស្សនៈនៃការអភិវឌ្ឍ គ្រួសារ និងសន្តិភាព ទប់ស្កាត់អំពើហឹង្សាក្នុងគ្រួសារ និងសមភាពយេនឌ័រ។

ការស្រលាញ់របស់គាត់ឋ ចំពោះការងារអភិវឌ្ឍន៍សហគមន៍ បានជម្រុញទឹកចិត្តខ្លួនឯង ឧទាហរណ៍ ដូចជាការបង្រៀន និងចែករំលែកមេរៀនដែលគាត់បានរៀន ទៅកាន់ប្រជាជនជាច្រើន។ ជាលទ្ធផល គាត់ត្រូវបានជាប់ឆ្នោតជាសមាជិក គណៈកម្មការទ្រទ្រង់សាលា (គ.ទ.ស) និងជាសមាជិកគណៈកម្មាធិការសហគមន៍កសិកម្មផងដែរ។ ក្រៅពីនេះទៀតនោះគាត់ក៏មានតំណែងជាអនុប្រធានភូមិ និងជាសមាជិក គណៈកម្មាធិការអភិវឌ្ឍន៍ភូមិផងដែរ។ គាត់ក៏បានជួយដល់គ្រួសារក្រីក្រ នៅក្នុង ក.ជ.ខ ក្នុងការដាំបន្លែ និងចិញ្ចឹមត្រីប្រកបដោយប្រសិទ្ធភាព ក៏ដូចជាធ្វើការពិគ្រោះយោបល់ទៅដល់គ្រួសារណា ដែលជួបបញ្ហាអំពើហឹង្សា ក្នុងគ្រួសារ។ គាត់ក៏បានណែនាំឪពុកម្តាយក្នុងការគាំទ្រកូនៗរបស់ពួកគាត់ ឱ្យបានទៅសាលារៀន ហើយក្នុងមួយឆ្នាំម្តង គាត់ជួយសម្របសម្រួលដល់ការជួបជុំនៅក្នុងភូមិ និងលើកទឹកចិត្តឱ្យអ្នកភូមិធ្វើការបញ្ចេញមតិ។ គាត់ក៏ខំព្រឹងព្យាយាមឱ្យស្ត្រី និងកុមារចូលរួមក្នុងដំណើរការរៀបចំផែនការឃុំសង្កាត់ផងដែរ។

ដូចរូបភាពដែលបានបង្ហាញខាងលើនេះ គាត់បានធ្វើការចូលរួម និង មានទំនួលខុសត្រូវលើការធ្វើឱ្យសហគមន៍របស់គាត់ប្រសើរឡើង។ ស្របពេលជាមួយគ្នានេះដែរ រាល់អ្វីដែលគាត់បានធ្វើគឺបង្ហាញឱ្យឃើញថា ស្ត្រីក៏អាចមានភារកិច្ច និងភាពជាអ្នកដឹកនាំស្មើនឹងបុរសដែរ។ គាត់បានក្លាយជាគំរូដ៏ល្អសម្រាប់អ្នកភូមិរបស់គាត់ ហើយក៏ជាគំរូសម្រាប់រដ្ឋាភិបាលនៅថ្នាក់ស្រុក និងខេត្តផងដែរ។ គាត់គឺជាភស្តុតាងនៃការអនុវត្តជាក់ស្តែងនៃសមភាពយេនឌ័រ ហើយគាត់បានជម្រុញឱ្យអាជ្ញាធរមូលដ្ឋាន និងប្រជាជនកម្ពុជាផ្សេងទៀតឱ្យមានភាពសកម្មក្នុងការបញ្ជ្រាបសមភាពយេនឌ័រ និងដើម្បីឱ្យការពង្រឹងសិទ្ធិអំណាចទៅដល់ស្ត្រីត្រូវបានដឹងលឺ ឱ្យមានការចូលរួម និងទទួលខុសត្រូវ។ នេះគឺជាអត្ថន័យនៃពាក្យស្លោករបស់អង្គការអាយស៊ីស៊ី ដែលនៅពេលសហគមន៍ ត្រូវបានពង្រឹងសិទ្ធិអំណាចរបស់ខ្លួន នោះវានឹងជះឥទ្ធិពលវិជ្ជមានមកដល់ប្រទេសជាតិផងដែរ។ ដូចច្នេះហើយទើប អង្គារអាយស៊ីស៊ី ជឿជាក់ថា *ពង្រឹងសហគមន៍ ជាតិរឹងមាំ។*

កាលបរិច្ឆេទ៖ សីហា ២០១៩